# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ
## ក្រោមប្រធានបទ ការសាកល្បងវិភាគអំពីតំណាងរាស្ត្ររបស់គណបក្ស ប្រជាជន ជាតំណាងបក្សរបស់ខ្លួន ឬជាតំណាងខ្មែរទាំងមូល ?

**Website: www.hoksavann.org**

ថ្ងៃទី១ មករា ២០១០



យើងពិនិត្យមើលរាល់ការប្រជុំរបស់សភាជាតិខ្មែរ ដើម្បីអនុម័តអំពីបញ្ហាអ្វីមួយតាមសំណើរបស់រដ្ឋាភិបាលខ្មែរ តំណាងរាស្ត្រនៃគណបក្សអ្នកកាន់អំណាចនិងគណបក្សប្រឆាំង មានសកម្មភាពផ្សេងគ្នា ។ សមាជិកសភានៃគណបក្សប្រជាជនដែលជាគណបក្សកាន់អំណាច ហាក់ដូចជាគ្មានខ្វល់ខ្វាយអ្វីឡើយ រង់ចាំតែលើកដៃអនុម័តតាមសំណើរបស់រាជរដ្ឋាភិបាលប៉ុណ្ណោះ ។ បានសេចក្តីថា ចាំតែយល់ស្របតាមសំណើនោះប៉ុណ្ណោះ ដោយពុំបានពិនិត្យមើលពិចារណាឲ្យបានល្អិតល្អន់ សាកសួរដេញដោលឲ្យបានច្បាស់លាស់មុននឹងអនុម័ត ។ បើមានឡើងនិយាយវិញ គ្មានអ្វីក្រៅពីសរសើររាជរដ្ឋាភិបាល ការពាររាជរដ្ឋាភិបាល ហើយនិងនិយាយរិះគន់គណបក្សប្រឆាំងប៉ុណ្ណោះ ។ បើគណបក្សប្រឆាំងនិយាយមិនយល់ស្របត្រង់ចំណុចណាមួយក្នុងសំណើរបស់រាជរដ្ឋាភិបាល សភានៃគណបក្សកាន់អំណាចនិយាយការពារជួសមុខឲ្យរាជរដ្ឋាភិបាល ជជែកជាមួយតំណាងរាស្ត្រនៃគណបក្សប្រឆាំងខុសពីមុខងាររបស់ខ្លួនទៅវិញ ។

ចំណែកគណបក្សសម-រង្ស៊ីជាគណបក្សប្រឆាំង ឡើងនិយាយហាក់ដូចជាប្រយ័ត្នប្រយែងណាស់ ព្រោះខ្លាចគេកាត់មិនឲ្យនិយាយជាបន្តទៅទៀត ។ ជួនកាលសមាជិកសភានៃគណបក្សប្រឆាំងនិយាយប៉ះពាល់ដល់រាជរដ្ឋាភិបាល ប្រធានអង្គប្រជុំបាននិយាយកាត់ឲ្យឈប់ដោយយកលេសថា និយាយចាកប្រធាន ។ គណបក្សប្រឆាំងគេបើកសិទ្ធិឲ្យឡើងនិយាយ ប៉ុន្តែទោះបីនិយាយល្អ ការពារផលប្រយោជន៍ប្រជាពលរដ្ឋក្នុងច្បាប់នោះយ៉ាងណាក៏ដោយ គេពុំដែលកែតាម ឬអនុម័តតាមឡើយ ។ បានសេចក្តីថា និយាយអ្វីនិយាយទៅ គេមិនខ្វីតាម សមនឹងគណបក្សប្រឆាំងមានសម្លេងក្នុងរដ្ឋសភាតិចផង ចំណែកគណបក្សកាន់អំណាចមានតំណាងរាស្ត្រ៩០ ជាងពីរភាគបីនៃតំណាងរាស្ត្រទាំងមូល ដូច្នេះទោះបីគណបក្សប្រឆាំងមិនយល់ព្រមអនុម័ត ក៏គណបក្សកាន់អំណាចនៅតែឈ្នះ ។

មុខនាទីសំខាន់ៗរបស់តំណាងរាស្ត្រ គឺសំណើច្បាប់និងអនុម័តច្បាប់ តាមដានមើលសកម្មភាពរបស់រដ្ឋាភិបាល ចុះទៅសួរសុខទុក្ខប្រជាពលរដ្ឋ ដើម្បីយកបញ្ហាមកដោះស្រាយ ។ ក្នុងន័យនេះ បើសភាតំណាងរាស្ត្រចាំតែហែអើសំណើរបស់រាជរដ្ឋាភិបាលខ្មែរ មិនពិនិត្យពិចារណាឲ្យម៉ត់ចត់មុននឹងអនុម័តច្បាប់ណាមួយ ចាត់ជាការពុំគោរពមុខនាទីរបស់ខ្លួនជាតំណាងរាស្ត្រ ព្រោះការបង្កើតឲ្យមានរដ្ឋសភាដែលជានីតិបញ្ញត្តិនេះ ដើម្បីតាមដានពិនិត្យសកម្មភាពរបស់រាជរដ្ឋាភិបាលដែលខ្លួនបង្កើត ដើម្បីឲ្យដឹងថាសកម្មភាពទាំងនោះបំរើផលប្រយោជន៍ប្រជាពលរដ្ឋ និងប្រយោជន៍ជាតិឬទេ ? ពេលដឹងហើយ ត្រូវចាត់វិធានការ បើមានការប្រព្រឹត្តខុសឆ្គងត្រូវហៅសួរដេញដោល ត្រូវដកពីតំណែងជាដើម តាមកំហុសរបស់ថ្នាក់ដឹកនាំ ។ រដ្ឋសភាត្រូវឯករាជ្យដាច់ចេញពីរាជរដ្ឋាភិបាល ចុះបើរដ្ឋសភានៅជាមួយរាជរដ្ឋាភិបាល ហើយមានពេលខ្លះដើរតួនាទីជួសរាជរដ្ឋាភិបាលផង តើចាំបាច់ត្រូវមានរដ្ឋសភាធ្វើអ្វី ? សភាតំណាងរាស្ត្រត្រូវតែការពារគ្នាឯង ផ្ទុយទៅវិញគ្រាន់តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ស្នើឲ្យដកអភ័យឯកសិទ្ធិពីតំណាងរាស្ត្រគណបក្សប្រឆាំង រដ្ឋសភាប្រញាប់ប្រញាល់ដកភ្លាម ។ រហូតប្តឹងតំណាងរាស្ត្រគណបក្សប្រឆាំងឡើងតុលាការ ដោយមូលហេតុគ្រាន់តែដកបង្គោលតម្រុយព្រំដែន ដែលបោះចូលមកដីស្រែពលរដ្ឋខ្មែរនៅស្រុកចន្ទ្រាខេត្តស្វាយរៀង ។ បង្គោលនោះ តាមការពិនិត្យមើលតាមរូបភាពក្នុងវីដេអូ គ្មានតម្លៃអ្វីឡើយ ហើយចោទថាធ្វើឲ្យខូចប្រយោជន៍សាធារណៈ ។ មិនតែប៉ុណ្ណោះបានចាប់ខ្លួនប្រជាពលរដ្ឋខ្លះផង ។ បើនិយាយតាមច្បាប់វិញ ប្រជាពលរដ្ឋត្រូវដាក់ពាក្យប្តឹងអាជ្ញាធរ អំពីបទបោះបង្គោលតម្រុយនៅក្នុងដីស្រែរបស់ខ្លួន ដោយពុំបានសុំអនុញ្ញាត ទើបត្រឹមត្រូវមានយុត្តិធម៌ ។ ដីស្រែនោះជាកម្មសិទ្ធិឯកជន រដ្ឋមករំលោភលើដីកម្មសិទ្ធិឯកជន ត្រូវទទួលទោសតាមច្បាប់ គឺសម-ភាពចំពោះមុខច្បាប់ ។ យើងមិនយល់ថា ពលរដ្ឋដកបង្គោលដើម្បីការពារដីស្រែរបស់ខ្លួនទៅជាមានទោសជាប់គុក ចំណែកអ្នកមានទោសបែរជារួចខ្លួន ហើយមានអំណាចចាប់គេដាក់គុកទៀត ។ សកម្មភាពនេះស្របតាមពាក្យមួយថា ចោរលួចរួចខ្លួនម្ចាស់ទ្រព្យជាប់គុក ។ នេះហើយជាច្បាប់ស្រុកខ្មែរ អ្នកណាខ្លាំងមានអំណាចត្រូវតែឈ្នះលើពលរដ្ឋទន់ខ្សោយគ្មានអំ-ណាច ដូចរឿងឆ្កែចចកនិងសត្វចៀម ។ គំនិតអ្នកធំខ្មែររបៀបនេះហើយ ដែលទឹកដីខ្មែរពីដើមធំទូលំទូលាយ រហូតនៅរួមតូចដូចសព្វថ្ងៃនេះ ដោយក្តីមានះមិនព្រមទទួលយកយោបល់ពីប្រជាពលរដ្ឋគ្រប់កន្លែង ដើម្បីជាការបង្រួបបង្រួមជាតិនិងរួមយោបល់ ដើម្បីស្ថាបនាជាតិឲ្យមានវឌ្ឍនភាព និងដើម្បីជៀសវាងទំនាស់គ្នា ។ យើងដឹងហើយថា រាជរដ្ឋាភិបាលនិងស្ថាប័នដទៃទៀតទទួលខុសត្រូវផ្ទាល់ចំពោះវាសនាជាតិ ប៉ុន្តែត្រូវមានការចូលរួមពីប្រជាពលរដ្ឋគ្រប់កន្លែងផង ទើបមានប្រសិទ្ធិភាព ។ កុំឲ្យមានពាក្យរិះគន់ថា ខ្មែរខាំគ្នាដូចសត្វឆ្កែ ពូកែតែខ្មែរគ្នាឯង សម្លាប់តែខ្មែរគ្នាឯង ធ្វើទុក្ខទោសបានតែអ្នកទន់ខ្សោយជាងខ្លួន ។

អំពីសកម្មភាពនៃតំណាងរាស្ត្រដែលកាន់របបប្រជាធិបតេយ្យ មាននៅសហរដ្ឋអាមេរិកជាដើម តំណាងរាស្ត្រគេមានឯករាជ្យ គេតែងតែមានសិទ្ធិរិះគន់ទៅលើរដ្ឋាភិបាល ទោះបីរដ្ឋាភិបាលនោះនៅក្នុងគណបក្សរបស់ខ្លួនក៏ដោយ ជាពិសេសមានការពិភាក្សាយ៉ាងល្អិតល្អន់នៅក្នុងរដ្ឋសភាចំពោះសំណើណាមួយ ដែលស្នើឡើងដោយរដ្ឋាភិបាល ។ ឧទាហរណ៍នៅសហរដ្ឋអាមេរិកមានគណបក្សពីរគឺគណបក្សសាធារណរដ្ឋនិងគណបក្សប្រជាធិបតេយ្យ ទោះបីប្រធានាធិបតីកើតចេញពីគណបក្សណាមួយក៏ដោយ ពេលធ្វើសំណើទៅរដ្ឋសភា រដ្ឋសភានៃគណបក្សទាំងពីរតែងតែសួរដេញដោលដោយឯករាជ្យមុននឹងធ្វើសច្ចានុម័តិ ។ បានសេចក្តីថា បើប្រធានាធិបតីនោះកើតចេញមកពីគណបក្សសាធារណរដ្ឋ តំណាងរាស្ត្ររបស់គណបក្សសាធារណរដ្ឋក៏ដូចជាតំណាងរាស្ត្ររបស់គណបក្សប្រជាធិបតេយ្យដែរ តែងតែពិភាក្សាសួរដេញដោលគ្រប់សំ-ណើរបស់ប្រធានាធិបតី មុននឹងអនុម័តយល់ព្រម ឬមិនយល់ព្រម ។ ត្រង់នេះហាក់ដូចជាមានលក្ខណៈខុសគ្នាពីសភាខ្មែរគឺសំណើពីរាជរដ្ឋាភិបាល សភាពីគណបក្សប្រជាជនមិនឃើញសួរដេញដោលអ្វីឡើយ រង់ចាំតែលើកដៃយល់ព្រម បើមានឡើងនិយាយ ក៏និយាយសរសើរសំណើរបស់រាជរដ្ឋាភិបាលនោះ និងនិយាយបន្ទុះបង្អាប់គណបក្សប្រឆាំងទៅវិញ ព្រោះគេឃើញសភារបស់គណបក្សប្រជាជនអនុម័តទាំងស្រុង នូវសំណើរបស់រាជរដ្ឋាភិបាល ដូចជាសំណើច្បាប់ធ្វើអស្សាមិករណ៍ ច្បាប់ធ្វើបាតុកម្មជាដើម ដោយគ្មានកែប្រែអ្វីឡើយ សូម្បីតែអក្ខរាវិរុទ្ធមួយក៏គ្មានកែដែរ ហើយទោះបីគណបក្សប្រឆាំងសុំឲ្យកែកន្លែងខ្លះ ក៏គ្មានបានផលអ្វីឡើយ ។ សភាតំណាងរាស្ត្រនៃគណបក្សកាន់អំណាចនិងគណបក្សប្រឆាំងគួរទុកជាដៃគូធ្វើការជាមួយគ្នា ដើម្បីឲ្យប្រទេសមានសន្តិភាពនិងវឌ្ឍនភាព មិនគួរទុកគ្នាជាសត្រូវឡើយ ។ ដូចបានពោលមកហើយ តើតំណាងរាស្ត្រនៃគណបក្សប្រជាជន ជាតំណាងបក្សរបស់ខ្លួន ឬជាតំណាងខ្មែរទាំងមូល ? ។៚

❊ ❊

❊